ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំពិភាក្សាជាមួយអ្នកវិនិយោគ និងក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត (PPSEZ)

តបតាមការអញ្ជើញរបស់លោកជំទាវ ឧកញ៉ា **លឹម ឈីវហូ** អគ្គនាយិកាក្រុមហ៊ុន ភ្នំពេញអេសអ៊ីហ្សិត (PPSEZ) នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ៩:០០ ព្រឹក ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងសហការីបានជួបប្រជុំសំណេះសំណាលជាមួយអ្នកអភិវឌ្ឍន៍តំបន់និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញប្រមាណ ៧៥ សហគ្រាស ដែលក្នុងនោះមានសហគ្រាសជាវិនិយោគិនជប៉ុនចំនួន ៤២ សហគ្រាស។



នៅក្នុងកិច្ចសំណេះសំណាលនេះ លោកជំទាវ ឧកញ៉ា **លឹម ឈីវហូ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការអញ្ជើញចូលរួមរបស់ប្រតិភូអគ្គនាយកដ្ឋានពន្ធដារដែលបានមកចូលរួមដោះស្រាយនូវរាល់ចង្ងល់របស់អ្នកវិនិយោគិនទាំងអស់ និងបានលើកនូវសំណើចំនួន ៤ មកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីជួយដោះស្រាយដែលរួមមាន÷

១.ស្នើសុំជួយសម្រួលលើកទឹកចិត្តផ្នែកពន្ធចំពោះអ្នកអភិវឌ្ឍន៍តំបន់និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស។

២-ស្នើសុំជួយសម្រួលការបង់ពន្ធកាត់ទុកលើការជួលដីរយៈពេលវែងដែលក្រុមហ៊ុនមិនទាន់បានបង់តាមតំណាក់កាលជាខែ។

៣-ស្នើសុំលើកលែងការបង់ពន្ធបន្ថែម និងការប្រាក់ចំពោះពន្ធកាត់ទុកលើការជួលដីរយៈពេលវែងដែលក្រុម ហ៊ុនមិនទាន់បានបង់។

៤-ស្នើសុំបង្កើតការិយាល័យពន្ធដារក្នុងច្រកចេញចូលតែមួយជាមួយស្ថាប័នដទៃទៀត ដើម្បីសម្រួលការប្រតិបត្តិរបស់អ្នកអភិវឌ្ឍន៍តំបន់ និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេសឲ្យកាន់តែមានលក្ខណៈប្រសើរ និងឆាប់រហ័ស។





ឆ្លើយតបនិងសំណើរបស់លោកជំទាវ ឧកញ៉ា **លឹម ឈីវហូ** ឯកឧត្តម **គង់ វិបុល** បានអរគុណលោកជំទាវឧកញ៉ា **លឹម ឈីវហូ** និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលបានអញ្ជើញរូបឯកឧត្តម និងសហការី ហើយឯកឧត្តមបានដោះស្រាយនូវរាល់ចម្ងល់របស់អ្នកវិនិយោគិនទាំងអស់ ដែលមានដូចខាងក្រោម÷

១-តំបន់សេដ្ឋកិច្ចពិសេសមានន័យថាមានការលើកទឹកចិត្តពិសេសហើយ។

២-គោលនយោបាយរបស់រាជរដ្ឋាភិបាលអណត្តិទី៥ នេះគឺតម្រូវឲ្យមានការកែទម្រង់ស៊ីជម្រៅ ដូច្នេះអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់ការគ្រប់គ្រងអភិបាលកិច្ចល្អរបស់ខ្លួន ដើម្បីពង្រឹងនូវការគោរពច្បាប់ឲ្យកាន់តែមានភាពប្រសើរឡើងថែមទៀត។

៣-អគ្គនាយកដ្ឋានពន្ធដារជាអង្គភាពប្រតិបត្តិច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ គឺមិនមែនជាអ្នកធ្វើគោលនយោបាយពន្ធដារទេ។ បញ្ហាណាដែលអគ្គនាយកដ្ឋានពន្ធដារមិនអាចដោះស្រាយពុំបាន អគ្គនាយកដ្ឋានពន្ធដារនឹងស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាអ្នកធ្វើគោលនយោបាយ ពន្ធដារពិនិត្យ និងសម្រេច។

៤-ចំពោះការស្នើសុំឲ្យបង្កើតការិយាល័យពន្ធដារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ឯកឧត្តម **គង់ វិបុល** បានយល់ថាការដាក់មន្ត្រី ប្រចាំការមកពីស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស គឺដើម្បីសម្រួលតម្រូវការនៃកិច្ចការប្រតិបត្តិប្រចាំថ្ងៃរបស់ វិនិយោគិនដែលក្នុងនោះរួមមាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំណែកឯអគ្គនាយកដ្ឋានពន្ធដារពុំបានដាក់មន្ត្រីប្រចាំការនោះទេ ដោយហេតុថាកិច្ចការពន្ធដារគឺមិនតម្រូវឲ្យវិនិយោគិនរាយការណ៍មកពន្ធដារជាប្រចាំថ្ងៃនោះទេ គឺតម្រូវឲ្យធ្វើការ ប្រកាសពន្ធប្រចាំខែ មួយខែម្តង និងប្រកាសពន្ធលើប្រាក់ចំណេញនៅចុងឆ្នាំតែ

ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត អគ្គនាយកដ្ឋានពន្ធដារនឹងដាក់ឲ្យប្រើប្រាស់នូវការប្រកាសពន្ធតាម Online នៅក្នុងពេលឆាប់ៗខាងមុខនេះ។ ដូច្នេះ វិនិយោគិនពុំចាំបាច់ចំណាយពេលវេលាធ្វើដំណើរមកអគ្គនាយកដ្ឋានពន្ធដារទៀតនោះទេ គឺអាចធ្វើការប្រកាសពន្ធតាម Online ពីការិយាល័យរបស់ក្រុមហ៊ុនបាន។ ចំពោះការធ្វើសវនកម្មគឺអគ្គនាយកដ្ឋានបញ្ជូនមន្ត្រីមកធ្វើការជាមួយ ក្រុមហ៊ុន គឺមិនតម្រូវឲ្យក្រុមហ៊ុនទៅជួបមន្ត្រីនោះទេ ហើយការបណ្តុះបណ្តាល និងសិក្ខាសាលានានាអំពីបទប្បញ្ញត្តិពន្ធដារអាចធ្វើនៅសាលាជាតិពន្ធដារ ឬអាចបញ្ជូនមន្ត្រីមកធ្វើបទបង្ហាញនៅតំបន់សេដ្ឋកិច្ចពិសេសនេះទៅតាមតម្រូវការ ជាក់ស្តែងប្រសិនបើចាំបាច់។

៥.ចំពោះការស្នើសុំបង់ពន្ធកាត់ទុកលើការជួលដីរយៈពេលវែង អគ្គនាយកដ្ឋានពន្ធដារនឹងលើកសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេច ។

៦.ចំពោះការបង្វិលសងអាករលើតម្លៃបន្ថែមដែលមានការយឺតយ៉ាវបណ្តាលមកពីអគ្គនាយកដ្ឋានពន្ធដារធ្វើការផ្ទៀងផ្ទាត់ដោយដៃនូវវិកយបត្រទាំងឡាយដែលត្រូវចំណាយពេលច្រើន ហើយអគ្គនាយកដ្ឋានពន្ធដារកំពុងរៀបចំ ទំនើបកម្មប្រព័ន្ធកុំព្យូទ័រដែលជួយសម្រួលឲ្យការពិនិត្យផ្ទៀតផ្ទាត់បានឆាប់រហ័ស។ ដូច្នេះនៅក្នុងពេលដ៏ខ្លីខាងមុខនេះ យើងនឹងអាចធ្វើការបង្វិលសងបានឆាប់រហ័សតាមការស្នើសុំរបស់ក្រុមហ៊ុនបាន។

៨.រាល់កិច្ចការពន្ធដែលពាក់ព័ន្ធនិងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស យើងនឹងចាត់ទុកជា**កិច្ចការអាទិភាព** ដោយផ្តល់សេវាឲ្យបានឆាប់រហ័ស។ ដូច្នេះសូមឲ្យមានការជឿជាក់ចំពោះអគ្គនាយកដ្ឋានពន្ធដារចំពោះការផ្តល់សេវា នេះ។

៩.ចំពោះពន្ធលើប្រាក់បៀវត្សដែលស្នើសុំឲ្យបង្កើនកម្រិតប្រាក់បៀវត្សជាប់ពន្ធពី ៥០ ម៉ឺនរៀលទៅខ្ពស់ជាង នេះដោយមូលហេតុកំរិតប្រាក់បៀវត្សអប្បបរមាត្រូវបានតម្លើងរហូតដល់ ១០០ ដុល្លានោះ អគ្គនាយកដ្ឋានពន្ធដារនឹង លើកសំណើនេះជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយបញ្ហានេះក៏មានការលើកឡើងរបស់វិស័យឯកជនដែរ។ បច្ចុប្បន្នមានរោងចក្រកាត់ដេរមួយចំនួនដែលមានការតវ៉ាមិនព្រមបង់ពន្ធលើប្រាក់បៀវត្សនេះ ក៏ប៉ុន្តែក្រោយការ ពន្យល់ពីមន្ត្រីពន្ធដារ ហាក់មានការយល់ដឹងពីកាតព្វកិច្ចនេះដោយកម្មករនិយោជិតមួយចំនួនបង់តែ ២០០០ រៀល ទៅ ៨០០០ រៀលតែប៉ុណ្ណោះ ហើយការបង់ពន្ធនេះមានន័យថាគាត់បានបំពេញកាតព្វកិច្ចចូលរួមចំណែកបង់ពន្ធជូនរដ្ឋ។ បញ្ហាមួយចំនួនទៀតកើតឡើងដោយសារក្រុមហ៊ុនធ្វើការគណនាការកាត់ទុកមិនបានត្រឹមត្រូវតាមច្បាប់ដែលធ្វើឲ្យមានការតវ៉ា។

១០.ចំពោះការស្នើសុំលើកលែងអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់របស់ក្រុមហ៊ុននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដល់ក្រុមហ៊ុនក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចគ្នាសម្រាប់ការនាំចេញ ១០០% ដូចអ្វីដែលបានផ្តល់ជូនចំពោះ ឧស្សាហកម្មគាំទ្រអគ្គនាយកដ្ឋានពន្ធដារនឹងលើកសំណើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យសម្រេច។

ក្រោយពីបានដោះស្រាយនូវសំណើ និងចម្ងល់ពីវិនិយោគិនទាំងអស់ កិច្ចសំណេះសំណាលបានបញ្ចប់នៅវេលា ម៉ោង ១២.០០ ថ្ងៃត្រង់ ដោយបរិយាកាសរីករាយ និងស្និតស្នាល។

**អគ្គនាយកដ្ឋានពន្ធដារ**